Clearing for Results Project - Phase IV

# វឌ្ឍនភាពនៃការអនុវត្តគម្រោង
## លើកកម្ពស់បរិយាបន្នបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
## សម្រាប់ជនរងគ្រោះដោយសារគ្រាប់មីនឬសំណល់ជាតិផ្ទុះនៃសង្គ្រាម
## (ពីថ្ងៃទី ០១ ខែសីហា ដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២៤)

ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៤ តាមរយៈអង្គការ UNDP អង្គការជនពិការកម្ពុជាបានទទួលមូលនិធិពី KOICA ដើម្បីអនុវត្តគម្រោងបណ្តុះបណ្តាលជំនាញដល់ជនរងគ្រោះដោយសារមីន ឬសំណល់ជាតិ ផ្ទុះពីសង្គ្រាម ឬ សមាជិកគ្រួសាររបស់ពួកគេ។ អង្គការជនពិការកម្ពុជាបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ អង្គការជនពិការតាមខេត្តចំនួនបួនសម្រាប់គម្រោងការបណ្តុះបណ្តាលជំនាញនិងជួយពួកគេក្នុងការអភិវឌ្ឍដូចជាប្រមូលទិន្នន័យជនរងគ្រោះដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមនិង/ឬគ្រួសាររបស់ពួកគេ ទិន្នន័យអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញនៅក្នុងតំបន់គោលដៅ។ ធ្វើការវាយតម្លៃតម្រូវការបណ្តុះបណ្តាលជាមួយជនរងគ្រោះដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម ឬសមាជិកគ្រួសារ ហើយសម្របសម្រួលបញ្ជូនជនរងគ្រោះដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមឬសមាជិកគ្រួសាររបស់ពួកគេទៅកាន់កន្លែងផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈដែលពាក់ព័ន្ធ។ល។

ក្នុងខែសីហានេះអង្គការជនពិការកម្ពុជាបានធ្វើការជាមួយអង្គការជនពិការដែលបានជ្រើសរើសក្នុងខេត្តគោលដៅទាំងបីដើម្បីគាំទ្រដល់ការអនុវត្តគម្រោងរបស់ពួកគេអោយឆ្លើយតបនឹង ឯកសារកិច្ចព្រមព្រៀងរបស់អង្គការជនពិការកម្ពុជាជាមួយអង្គការ UNDP ។ ជាលទ្ធផល អង្គការជនពិការតាមខេត្តដែលបានជ្រើសរើសទាំង ៤ នៅខេត្តប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះកន្លែងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសាធារណៈនិងឯកជនជន និងទិន្នន័យពិការភាពជាជនរងគ្រោះដោយសារមីនឬសំណល់គ្រឿងផ្ទុះនៅក្នុងឃុំ/ស្រុកគោលដៅ។ អង្គការជនពិការតាមខេត្តបានធ្វើការផ្សព្វផ្សាយការយល់ដឹងអំពីវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចំពោះជនរងគ្រោះដោយសារមីនឬសំណល់ជាតិផ្ទុះពីសង្គ្រាមឬក្រុមគ្រួសាររបស់ពួកគេនិងបានធ្វើការវាយតម្លៃជំនាញត្រូវការបណ្តុះ បណ្តាលជាមួយជនរងគ្រោះដោយសារមីនឬសំណល់ជាតិ ផ្ទុះពីសង្គ្រាមឬក្រុមគ្រួសាររបស់ពួកគេផងដែរ។



ក្នុងកំឡុងខែនេះ អ្នកទទួលផលចំនួន ៩នាក់ ដែលជាជនរងគ្រោះដោយសារមីន/សំណល់គ្រឿងផ្ទុះឬសមាជិកគ្រួសាររបស់ពួកគេ (ស្រី ៦នាក់) ត្រូវបានចុះឈ្មោះសម្រាប់ការបណ្តុះបណ្តាលជំនាញ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈហើយបានបញ្ជូនទៅកន្លែងបណ្តុះបណ្តាលជំនាញដូចជា ៣ នាក់ រៀនជំនាញសាឡុន ២នាក់រៀនជំនាញកុំព្យូទ័រ ៣នាក់រៀនជំនាញកាត់ដេរ ១ នាក់រៀនជំនាញជុសជុលម៉ាស៊ីនត្រជាក់និងម៉ាស៊ីនបោកខោអាវ។

ក្នុងខែនេះដែរ អង្គការជនពិការកម្ពុជា បានផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលចំនួន ២ ថ្ងៃ ស្តីពី "ការសរសេរករណីសិក្សា និងការគ្រប់គ្រងអង្គការ និងភាពជាអ្នកដឹកនាំ" បានធ្វើឡើងនៅថ្ងៃទី ២៦- ២៧ ខែសីហា ឆ្នាំ ២០២៤ ដល់ អង្គការជនពិការដែលបានជ្រើសរើសក្នុងខេត្តគោលដៅនៃគម្រោង ដែលមានអ្នកចូលរួមសរុបចំនួន១០នាក់ (ស្រី ២នាក់) ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការសរសេរ ករណីសិក្សា និងការគ្រប់គ្រងអង្គការ និងភាពជាអ្នកដឹកនាំ។ ជាលទ្ធផលនៃការវាយតម្លៃវគ្គបណ្តុះបណ្តាលបានបង្ហាញថា អ្នកចូលរួម ៧៥% មានការយល់ដឹងល្អ ខណៈពេលដែល ២៥% មានកម្រិតមធ្យមលើគោលគំនិតជាមូលដ្ឋាននៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់អង្គការ មុខងារគ្រប់គ្រង តួនាទីអ្នកដឹកនាំអង្គការ និងរបៀបសរសេរករណីសិក្សាដើម្បីបង្ហាញពីសមិទ្ធផលគម្រោងរបស់អង្គការ។



ក្រៅពីនេះអង្គការជនពិការកម្ពុជាបានធ្វើការតាមដានត្រួតពិនិត្យជាប្រចាំដល់សិក្ខាកាមដែលបានចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញចាប់តាំងពីដើមឆ្នាំ២០២៤ ដល់ចុងខែសីហា ឆ្នាំ២០២៤នេះ មានសមាជិកគ្រួសារជនរងគ្រោះដោយសារមីនចំនួន ១៣៦ (ស្រី ៥១ នាក់) បានចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញ។

| លរ | អង្គការជនពិការ | ចំនួន | ប្រភេទជំនាញ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ជុសជុលម៉ូតូ | សំអាង | កុំព្យូទ័រ | កាត់សក់ | កាត់ដេរ | ផ្សារដែក | ជុសជុលទូរស័ព្ទ | បើកបររថយន្ត | ជួសជុលរថយន្ត | ជួសជុលម៉ាស៊ីនត្រជាក់ |
| ១- | អង្គការជនពិការខេត្តបាត់ដំបង | ៣៧ | ៣ | ៣ | ២០ | ៤ | ២ | ៣ | | | | ២ |
| ២- | អង្គការជនពិការស្រុកឯកភ្នំ | ៣៣ | ៤ | ៣ | ៧ | ២ | ៤ | | ៣ | ៥ | ៣ | ២ |
| ៣- | អង្គការជនពិការខេត្តប៉ៃលិន | ៣៣ | ២ | ១០ | ៨ | | ២ | ២ | | | ៤ | ៥ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤- | អង្គការជនពិការខេត្តបន្ទាយមានជ័យ | ៣៣ | ៨ | ១ | ៧ | ២ | ៩ | | | ៤ | ១ | ១ |
| | **សរុប** | **១៣៦** | **១៧** | **១៧** | **៤២** | **៨** | **១៧** | **៥** | **៣** | **៩** | **៨** | **១០** |

រហូតមកដល់ពេលនេះ មានចំនួន ៦០នាក់ (ស្រី ១៩នាក់) ដែលបានបញ្ចប់វគ្គជំនាញ។ ក្នុងនោះមាន២៩នាក់ (ស្រី១១នាក់) មានការងារធ្វើ ៧នាក់បើកអាជីវកម្មផ្ទាល់ខ្លួន និង១៧នាក់ (ស្រី៩នាក់) មិនទាន់មានការងារធ្វើនៅឡើយ ។



*រូបភាពប្រជុំផ្សព្វផ្សាយនៅសហគមន៍នៃគម្រោងជនរងគ្រោះដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមបនៅឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង*